# សង្កិច្ចជាតក

## មហានរក ៨ រណ្ដៅ

១.សញ្ជីវៈ



២.កាឡសុត្តៈ



៣.សង្ឃាតៈ



៤.ជាលរោរុវៈ



៥.ធូមរោរុវៈ



៦.តាបនៈ



៧.បតាបនៈ



៨.មហាអវីចិ



**ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សដ្ឋិនិបាត បិដកលេខ ៦១ ទំព័រ ៥៣**

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*ដឹកនាំប្រែដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង** **ព.ស. ២៥៦២**



ធម្មោ បថោ មហារាជ, អធម្មោ បន ឧប្បថោ;
អធម្មោ និរយំ នេតិ, ធម្មោ បាបេតិ សុគ្គតឹ

*បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌*
*នាំសត្វទៅកាន់នរក ធម៌ញុំាងសត្វឲ្យដល់សុគតិ*

# សន្ធិច្ឆជាតក

## បច្ចុប្បន្នវត្ថុ (រឿងរ៉ាវបច្ចុប្បន្ន)

*ព្រះសាស្ដា កាលស្ដេចគង់នៅជីវកម្ពវ័ន ទ្រង់ប្រារព្ធបិតុឃាតកម្មរបស់ព្រះបាទអជាសត្តុ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ទិស្វា និសិន្នំ រាជានំ** *ដូច្នេះជាដើម ។*

*ព្រះបាទអជាតសត្តុនោះ អាស្រ័យនឹងទេវទត្ត បានឲ្យគេសម្លាប់ព្រះបិតា តាមពាក្យរបស់ទេវទត្តនោះ (កាលកន្លងមក) បានស្ដាប់ថា ទេវទត្តមានបរិស័ទបែកគ្នា ក្នុងកាលទីបំផុត នៃការបំបែកសង្ឃ ហើយមានរោគកើតឡើង ទើបគិតថា យើងនឹងឲ្យព្រះតថាគតឲ្យអត់ទោសឲ្យ ដូច្នេះហើយបានទៅកាន់ក្រុងសាវត្ថី នូវភាពជាអ្នកចូលទៅកាន់ផែនដី ដោយគ្រែ*

ស្មេង ហើយត្រូវផែនដីស្រូបត្រង់ទ្វារវត្តជេតពន ទើបទ្រង់ត្រិះរិះថា ទេវទត្តជាបិដិបក្ខ ចំពោះព្រះសម្មាសម្ពុទ្ធ បានចូលទៅកាន់ផែនដី ជាអ្នកមានអវីចិ-នរកជាទីទៅខាងមុខ សូម្បីយើងបានឲ្យគេសម្លាប់ព្រះបិតាដែលជាព្រះធម្មរាជប្រកបដោយធម៌ អាស្រ័យនឹងទេវទត្តនោះ តើយើងនឹងត្រូវចូលទៅកាន់ផែនដីឬហ្ន៎ គិតដូច្នេះហើយ ទ្រង់ភ័យខ្លាច មិនបានសប្បាយចិត្តក្នុងសិរីរាជសម្បត្តិ ទ្រង់គិតទៀតថា យើងផ្ទំបន្តិចគ្រាន់តែផ្ទំបានបន្តិចប៉ុណ្ណោះ ក៏ប្រាកដដូចថា ត្រូវនាយនិរយបាល មកចាប់បោះចូលទៅមហាផែនដីដែកដែលមានកម្រាស ៩ យោជន៍ ហើយចាក់ដោយលំពែងដែក ឬប្រាកដដូចត្រូវសុនខខាំ ទើបទ្រង់ស្រែកដោយសំឡេងគួរឲ្យខ្លាច ហើយភ្ញាក់ឡើង ។

ថ្ងៃមួយ ក្នុងកាលជាទីបំផុតនៃរដូវភ្លៀង ខែទី ៤ ដែលជាពេលនៃការរីករបស់ផ្កាកុមុទ ព្រះបាទអជាត-សត្តុ ទ្រង់មានពួកអាមាត្យចោមរោម ទ្រង់សម្លឹងមើលយស របស់ខ្លួនហើយត្រិះរិះថា យសបិតារបស់យើងធំជាងនេះទៀត យើងបានឲ្យគេសម្លាប់ព្រះបិតា ដែលជាធម្មរាជា មានសភាពបែបនោះ ដោយអាស្រ័យទេវទត្ត ។ កាលព្រះបាទអជាតសត្តុ គិតយ៉ាងនេះហើយ សេចក្ដីក្ដៅក្រហាយ ក៏បានកើតឡើង ក្នុងព្រះកាយ សរីរកាយទាំងអស់ទៅជាបែកញើស ។ លំដាប់នោះ ព្រះអង្គគិតថា អ្នកណាហ្ន៎ អាចនឹងបន្ទោបង់ភ័យរបស់យើងបាន ដូចនេះហើយ ទ្រង់ជ្រាបថា វៀរលែងតែព្រះទសពលចេញហើយ បុគ្គលដទៃរមែងមិនមានរួចទ្រង់គិតថា យើងជាអ្នកមានកំហុសធំ ចំពោះព្រះតថាគត "អ្នកណាហ្ន៎ នឹងនាំយើងទៅគាល់ព្រះពុទ្ធ

បាន” ទ្រង់កំណត់ថា “អ្នកដទៃណាមួយក្រៅពីពេទ្យជីវក រមែងមិនមាន” យ៉ាងនេះ ទ្រង់កាន់យកពេទ្យជីវកនោះ កាលនឹងធ្វើឧបាយនៃការទៅ ទើបបន្ទឺឧទានថា ម្នាលអ្នកដ៏ចម្រើន រាត្រីយប់នេះ ព្រះចន្ទ្រប្រាសចាកទោស គួរជាទីរីករាយណាស់ហ្ន៎ ហើយទ្រង់ពោលថា ថ្ងៃនេះ យើងនឹងចូលទៅអង្គុយជិតសមណៈ ឬព្រាហ្មណ៍ណាហ្ន៎ ។ កាលអាមាត្យទាំងឡាយដែលជាសាវក របស់បូរណកស្សបៈជាដើមពោលគុណរបស់បូរណៈជាដើម ទ្រង់មិនអើពើនឹងពាក្យ របស់អាមាត្យទាំងនោះ ទើបសួរពេទ្យជីវក កាលពេទ្យជីវកពោលគុណ របស់ព្រះតថាគតហើយក្រាបទូលថា សូមទ្រង់ចូលទៅអង្គុយជិត ព្រះមានព្រះភាគនោះចុះ ដូច្នេះហើយ ព្រះអង្គឲ្យគេរៀបចំយានមានដំរីជាដើម យាងទៅជីវកម្ពវ័ន ចូលទៅគាល់ព្រះតថាគត ថ្វាយបង្គំ

ហើយ កាលដែលព្រះតថាគតធ្វើបដិសណ្ឋារ ទ្រង់ទើបទូលសួរសាមញ្ញផល ដែលនឹងគប្បីឃើញដោយខ្លួនឯង ទ្រង់ស្តាប់ព្រះធម្មទេសនា**សាមញ្ញផលសូត្រ** ក្នុងវេលាចប់ព្រះសូត្រ ទ្រង់បានប្រកាសព្រះអង្គ ជាឧបាសក ហើយសូមឲ្យព្រះតថាគតអត់ទោសឲ្យ រួចទើបយាង ចៀសចេញទៅ ។ ចាប់ពីពេលនោះ ព្រះបាទអជាតសត្តុនោះ កាលបានថ្វាយទាន រក្សាសីល ធ្វើការគប់រកមួយអន្លើដោយព្រះតថាគត កាលបានស្តាប់ធម្មកថា ដ៏ពីរោះ ព្រោះការសេពគប់កល្យាណមិត្ត ទ្រង់ទើបលះបង់ សេចក្តីភ័យខ្លាច សេចក្តីព្រឺរោម ក៏ប្រាសចាកទៅ ត្រឡប់បានការរីករាយចិត្ត សម្រេចនៅជាសុខ ដោយឥរិយាបថទាំង ៤ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយញ៉ាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ព្រះបាទអជាតសត្តុធ្វើបិតុឃាតកម្មហើយ ជាអ្នកដល់ នូវសេចក្តីភ័យខ្លាចកាលមិនបាន ការសប្បាយព្រះហឫទ័យ ដោយអាស្រ័យសិរីរាជសម្បត្តិ ទ្រង់សោយសេចក្តីទុក្ខ ក្នុងឥរិយាបថទាំងពួង តែឥឡូវនេះ ព្រះរាជានោះ មករកព្រះតថាគត ព្រោះការសេពគប់កល្យាណមិត្ត ទ្រង់ជាអ្នកប្រាសចាកភ័យ និងសោយឥស្សរិយសុខ ។ ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយពោលថា ដោយរឿងឈ្មោះនេះ ទ្រង់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ព្រះរាជានេះក៏បានធ្វើបិតុឃាតកម្ម ហើយ

ដោយអាស្រ័យតថាគត ទ្រង់ផ្ទំជាសុខ ដូចគ្នាដែរ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា

## អតីតវត្ថុ ( រឿងរ៉ាវអតីត )

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងនគរពារាណសី ទ្រង់មានព្រះរាជបុត្រមួយអង្គព្រះនាម **ព្រហ្មទត្តកុមារ** ។ ក្នុងគ្រានោះ ព្រះពោធិសត្វ កាន់យកបដិសន្ធិ ក្នុងផ្ទះរបស់បុរោហិត កាលលោក កើតមកហើយ ពពួកញាតិបានដាក់ឈ្មោះឲ្យលោកថា **សំកិច្ចកុមារ** ។ ព្រះរាជកុមារព្រហ្មទត្ត និងសំកិច្ចកុមារ ទាំងពីរនោះបានចម្រើនវ័យឡើងជាមួយគ្នាក្នុងរាជនិវេសន៍ ។ គេទាំងពីរបានជាសម្លាញ់នឹងគ្នា កាលធំដឹងក្តីហើយ បានទៅនគរតក្ក-

សិលា រៀនសិល្បសាស្រ្តទាំងពួង ចេះចប់រួចហើយ ទើបត្រឡប់មកវិញ ។

លំដាប់នោះ ព្រះរាជាក៏ប្រទាន តំណែងឧបរាជ ដល់ព្រះរាជបុត្រ ។ សូម្បីព្រះពោធិសត្វក៏ជាអ្នកនៅ ក្នុងសម្នាក់ឧបរាជនោះ ។ ថ្ងៃមួយ ឧបរាជឃើញយស ដ៏ធំរបស់ព្រះបិតាដែលកំពុងក្រសាលឧទ្យាន ក៏កើត សេចក្តីលោភក្នុងយសនោះ ហើយគិតថា បិតារបស់ យើង (មានវ័យ) ប្រៀបដូចបងរបស់យើង បើយើងរង់ ចាំមើលសេចក្តីស្លាប់ របស់បិតានោះ យើងនឹងបាន រាជសម្បត្តិក្នុងកាល ដែលយើងចាស់ជាមិនខាន រាជ-សម្បត្តិដែលយើងបាន ក្នុងកាលនោះ នឹងមាន ប្រយោជន៍អ្វី យើងនឹងឲ្យគេធ្វើឃាតព្រះបិតា ហើយ កាន់យករាជសម្បត្តិ គិតដូច្នេះហើយ ទើបប្រាប់ សេចក្តីនោះ ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វហាម

ឃាត់ថា ម្នាលសម្លាញ់ ឈ្មោះថា បិតុឃាតកម្ម ជាកម្មធ្ងន់ ជានិរយមគ្គ (ផ្លូវទៅកាន់នរក) អ្នកណាៗ មិនអាចនឹងធ្វើកម្មនោះបាន សូមព្រះអង្គកុំធ្វើអី ។ ឧបរាជនោះប្រាប់សេចក្ដីប្រាថ្នា របស់ខ្លួនរឿយ តែត្រូវព្រះពោធិសត្វហាមឃាត់ ដរាបដល់គ្រាទី ៣ ទើបប្ដូរទៅប្រឹក្សាជាមួយនឹងអ្នកជំនិត ។ ចំណែកអ្នកទាំងនោះទទួលព្រមហើយ ពិចារណាឧបាយធ្វើឃាតព្រះរាជា ។ ព្រះពោធិសត្វ ដឹងព្រឹត្តិការណ៍នោះហើយ គិតថា យើងនឹងមិននៅរួម ជាមួយមនុស្សពាល ទាំងនោះឡើយ ដូច្នេះហើយ ទើបមិនប្រាប់លាមាតាបិតា ចេញទៅតាមទ្វារធំ ចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសីញុំាងឈានអភិញ្ញាឲ្យកើតឡើង ជាអ្នកមានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារ រស់នៅជាសុខ ក្នុងព្រៃនោះឯង ។

ក្នុងពេលនោះ សូម្បីព្រះរាជកុមារ ក៏បានបញ្ជាឲ្យគេធ្វើឃាតព្រះបិតា ហើយសោយយសដ៏ធំ ។ ពួកកុលបុត្រទាំងឡាយ ជាច្រើនបានស្តាប់ថា បានឮមកថា សំកិច្ចកុមារបួសជាឥសី ដូច្នេះទើបនាំគ្នាចេញទៅហើយបួសក្នុងសម្នាក់សំកិច្ចកុមារនោះ ។ ព្រះសំកិច្ច-ឫសីនោះ មានពួកឫសីជាបរិវារដ៏ធំ រស់នៅក្នុងព្រៃហិមពាន្តនោះ ។ សូម្បីឥសីទាំងអស់ ក៏ជាអ្នកបានឈានសមាបត្តិ ។ ចំណែកព្រះរាជាកាលឲ្យគេសម្លាប់ព្រះបិតាហើយ បានសោយសុខក្នុងរាជសម្បត្តិ អស់កាលមានប្រមាណតិចប៉ុណ្ណោះ បន្ទាប់ពីនោះមកទ្រង់មានភ័យខ្លាច មិនសប្បាយព្រះហឫទ័យ ហាក់បីដូចជាបានទទួលកម្មក្នុងនរក ។ ព្រះរាជានោះ រលឹកដល់ព្រះពោធិសត្វហើយគិតថា សម្លាញ់របស់យើងហាមថា បិតុឃាតកម្មជាកម្មធ្ងន់ សូមព្រះអង្គកុំធ្វើ

កាលគេមិនអាចនឹងឲ្យយើង ជឿពាក្យរបស់ខ្លួន ទើបបានធ្វើខ្លួនឲ្យជាអ្នកមិនមានទោស រួចរត់ទៅ ។ បើគេនឹងនៅក្នុងទីនេះ គង់នឹងមិនឲ្យយើងធ្វើបិតុឃាតកម្ម នឹងគប្បីនាំចេញនូវភ័យ របស់យើង តើគេនៅក្នុងទីណាហ្ន៎ ? បើយើងដឹងទីនៅរបស់សំកិច្ចនោះ នឹងឲ្យគេហៅមក តើអ្នកណាហ្ន៎ ដែលនឹងប្រាប់ទីនៅ របស់សំកិច្ចនោះ បាន ។ ចាប់ពីពេលនោះមក ព្រះរាជានោះតែងត្រាស់សរសើរគុណ របស់ព្រះពោធិសត្វក្នុងអន្តបុរីផង ក្នុងរាជសភាផង ។

គ្រាកាលកន្លងទៅអស់កាលដ៏យូរ យ៉ាងនេះ ព្រះពោធិសត្វគិតថា ព្រះរាជារឭកយើង យើងគួរទៅក្នុងទីនោះ នឹងសម្តែងធម៌ដល់ព្រះអង្គ ធ្វើទ្រង់ឲ្យជាអ្នកមិនមានភ័យ ហើយសឹមត្រឡប់មក ដូច្នេះកាលនៅក្នុងព្រៃហិមពាន្តអស់ ៥០ ឆ្នាំហើយ សំកិច្ចតសីមានពួក

តាបស ៥០០ ជាបរិវារ នាំគ្នាមកតាមផ្លូវអាកាស ចុះក្នុងឧទ្យានឈ្មោះ ទាយបស្ស: ជាអ្នកមានពួកឥសីឡោមព័ទ្ធ អង្គុយលើផែនថ្ម ។ នាយឧទ្យានបាលឃើញព្រះពោធិសត្វហើយ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកជាសាស្ដារបស់គណៈឈ្មោះអ្វី គេបានស្ដាប់ថា ឈ្មោះថា **សំកិច្ចបណ្ឌិត** ដូច្នេះគេក៏ចាំបានហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះ ដរាបដល់ខ្ញុំនាំព្រះរាជាមក ព្រះរាជារបស់ខ្ញុំ ប្រាថ្នានឹងជួបលោកម្ចាស់ ពោលយ៉ាងនេះហើយ គេទៅកាន់រាជត្រកូលដោយប្រញាប់ ហើយប្រាប់ភាពជាអ្នកមក របស់ព្រះពោធិសត្វ ដល់ព្រះរាជា ។ ព្រះរាជាយាងទៅកាន់សម្នាក់ព្រះពោធិសត្វទ្រង់ធ្វើការបូជា ដែលសមគួរនឹងធ្វើ ហើយសួរបញ្ហា ។

ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

**ទិស្វា និសិន្នំ រាជានំ, ព្រហ្មទត្តំ រថេសភំ;**
**អថស្ស បដិវេទេសិ, យស្សាសិ អនុកម្បកោ។**

(ឧយ្យានបាលនោះ) ឃើញព្រះរាជា ទ្រង់ព្រះនាម ព្រហ្មទត្ត ប្រសើរក្នុងរថហើយក្រាបទូលព្រះរាជានោះ ក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈឺឆ្អាល ដល់ឥសីណា ។

**សំកិច្ចាយំ អនុប្បត្តោ, ឥសីនំ សាធុសម្មតោ;**
**តរមានរូបោ និយ្យាហិ, ខិប្បំ បស្ស មហេសិនំ។**

ឥសីឈ្មោះសង្កិច្ចនេះ ដែលគេសន្មតថា ជាសប្បុរសរបស់ពួកឥសីមកដល់ហើយ សូមព្រះអង្គ

*ប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់ ។*

តតោ ច រាជា តរមានោ, យុត្តមារុយ្ហ សន្ទនំ;
មិត្តាមច្ចបរិព្យូឡ្ហោ, អគមាសិ រថេសភោ។

*លំដាប់នោះ ព្រះរាជាប្រសើរក្នុងរថ មានមិត្តនិងអាមាត្យហែហម ទ្រង់ប្រញាប់ឡើងកាន់រថ ដែលគេទឹមហើយ ទ្រង់យាងទៅ ។*

និក្ខិប្ប បញ្ច ककុធានិ, កាសីនំ រដ្ឋវឌ្ឍនោ;
វាលពីជនិមុណ្ហីសំ, ខគ្គំ ឆត្តញ្ចុបាហនំ។

*ព្រះរាជា ញ៉ាំងដែននៃពួកកាសីឲ្យ ចម្រើនទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង គឺ ផ្លិតរោមសត្វ ១ មកុដ ១ ព្រះខាន់ ១ ឆត្រ ១ សុពណ៌បាទុកា ១ ។*

ឱរុយ្ហ រាជា យានម្ហា, ឋបយិត្វា បដិច្ឆទំ;
អាសីទិំ ទាយបស្សស្មឹ, សំកិច្ចមុបសង្កមិ។

*លុះព្រះរាជា ទ្រង់យាងចុះអំពីយាន ទុកគ្រឿង កកុធៈហើយទើប យាងចូលទៅរកសង្កិច្ចឥសី ដែលអង្គុយក្នុងឧទ្យានឈ្មោះទាយបស្សៈ ។*

ឧបសង្កមិត្វា សោ រាជា, សម្មោទិ ឥសិនា សហ;
តំ កថំ វីតិសារេត្វា, ឯកមន្តំ ឧបាវិសិ។

*ព្រះរាជានោះ ចូលទៅសំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់ពាក្យនោះហើយ ក៏គង់ក្នុងទីដ៏ សមគួរ ។*

ឯកមន្តំ និសិន្នោវ, អថ កាលំ អមញ្ញថ;
តតោ បាបានិ កម្មានិ, បុច្ឆិតុំ បដិបជ្ជថ។

*ព្រះរាជាគង់ស៊ប់ ក្នុងទីសមគួរហើយ ទើបទ្រង់ជ្រាបនូវកាល គួរប្រតិបត្តិ ដើម្បីសួរនូវបាបកម្មទាំងឡាយ ក្នុងពេលនោះ ។*

ឥសឹ បុច្ឆាម សំកិត្តំ, ឥសីនំ សាធុសម្មតំ;
អាសីនំ ទាយបស្សស្មឹ, ឥសិសង្ឃបុរក្ខតំ។

*យើងសូមសួរសង្កិច្ចឥសី ដែលគេសន្មតថា ជាសប្បុរសរបស់ពួកឥសី ដែលពួកឥសីចោមរោមហើយ គង់ក្នុងទាយបស្សឧទ្យាន ។*

កំ គតឹ បេច្ច គច្ឆន្តិ, នរា ធម្មាតិចារិនោ;
អតិចិណ្ណោ មយា ធម្មោ, តំ មេ អក្ខាហិ បុច្ឆិតោ។

*ពួកជនអ្នកប្រព្រឹត្តរំលងធម៌ លុះស្លាប់ទៅវិញ ទៅកាន់គតិណា ធម៌គឺបិតុឃាតកម្ម ខ្ញុំបានប្រព្រឹត្តកន្លង*

ហើយ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្ដីនោះ ដល់ខ្ញុំ ។

ពាក្យថា **លំដាប់នោះ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជានោះ លុះបានស្ដាប់ពាក្យរបស់នាយឧទ្យានបាលនោះ ក៏ប្រញាប់យាងទៅ បន្ទាប់ពីស្ដាប់ពាក្យរបស់ឧទ្យានបាលនោះ ។ ពាក្យថា **ទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង** សេចក្ដីថា បានឮថា ព្រះរាជានោះ លុះស្ដេចយាងទៅ ដល់ទ្វារឧទ្យានហើយ ទ្រង់គិតថា ឈ្មោះថា បណ្ឌិតទាំងឡាយជាអ្នកតាំងនៅក្នុងឋានៈ ដែលគួរគោរព យើងមិនគួរទៅកាន់សម្នាក់សំកិច្ចតាបស ដោយភេទដែលខ្ពង់ខ្ពស់ ព្រះអង្គទើបដោះគ្រឿងបញ្ចរាជកកុធភណ្ឌទាំងឡាយនេះ គឺ **វាលពីជនី** (ផ្លិត) ដែលមានដងជាមាស ប្រដាប់ដោយកែវមណី ១ **ឧណ្ហីសបដ្ដៈ** មកុដដែលធ្វើពីមាស ១ **មង្គលខគ្គៈ** ព្រះ

ខាន់មង្គលដែលហ៊ុមព័ទ្ធយ៉ាងល្អ ១ **សេតច្ឆត្តៈ** ស្វេតច្ឆត្រ ១ **សុវណ្ណបាទុកា** ទ្រនាប់ជើងមាស ១ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា ព្រះរាជាទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង ។ ពាក្យថា **ខ្ញុំបានប្រព្រឹត្តកន្លង** សេចក្ដីថា ព្រះបាទព្រហ្មទត្តកុមារសួរ សំកិច្ចតាបសថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំបានប្រព្រឹត្តកន្លងសុចរិតធម៌ គឺខ្ញុំបានធ្វើបិតុឃាតកម្ម សូមលោកម្ចាស់ប្រាប់ សេចក្ដីនោះដល់ខ្ញុំ បុគ្គលដែលសម្លាប់បិតានឹងទៅកាន់គតិដូចម្ដេច គឺនឹងឆេះក្នុងនរកដូចម្ដេច ?

ព្រះពោធិសត្វស្ដាប់ ពាក្យនោះហើយ ពោលថា បពិត្រមហារាជ បើយ៉ាងនោះ សូមទ្រង់ស្ដាប់ចុះ ហើយឲ្យឱវាទជាដំបូង ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ឥសី អវច សំកិច្ចោ, កាសីនំ រដ្ឋវឌ្ឍនំ;
អាសីនំ ទាយបស្សស្មឹ, មហារាជ សុណោហិ មេ។

សង្កិច្ចឥសី បានពោលនឹងព្រះរាជា អ្នកញុំាងដែនកាសីឲ្យចម្រើន គង់ក្នុងទាយបស្សឧទ្យានថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មា ភាព ។

ឧប្បថេន វជន្តស្ស, យោ មគ្គមនុសាសតិ;
តស្ស ចេ វចនំ កយិរ, ជាស្ស មគ្គេយ្យ កណ្ដកោ។

អ្នកណាប្រាប់ផ្លូវដល់បុគ្គល អ្នកដើរផ្លូវខុស បើបុគ្គលនោះ ធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្ទា (ចោរ) មិនគប្បីជួបនឹងបុគ្គលអ្នកធ្វើតាមនោះទេ ។

**អធម្មំ បដិបន្នស្ស, យោ ធម្មមនុសាសតិ;**
**តស្ស ចេ វចនំ កយិរា, ន សោ គច្ឆេយ្យ ទុគ្គតិំ។**

*អ្នកណាប្រៀន ប្រដៅធម៌ ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រដៅនោះ បុគ្គលនោះមិនគប្បីទៅកាន់ទុគ្គតិទេ ។*

*ពាក្យថា* ***បុគ្គលនោះ មិនគប្បីទៅកាន់ទុគ្គតិទេ*** *សេចក្ដីថា បុរសនោះ មិនគប្បីទៅកាន់ទុគ្គតិ មានប្រភេទនរកជាដើម ។ ពិតមែន អធម៌ដូចជាផ្លូវខុស ឯសុចរិតធម៌ដូចជាផ្លូវដ៏ក្សេម ចំណែកព្រះអង្គ ក្នុងកាលមុន ពោលនឹងអាត្មាថា យើងសម្លាប់ព្រះបិតាហើយនឹងបានជាព្រះរាជា អាត្មាបានហាមឃាត់ តែព្រះអង្គមិនធ្វើតាមពាក្យអាត្មា បានឲ្យគេសម្លាប់ព្រះបិតាហើយឥឡូវនេះ ព្រះអង្គមកសោយសោក ធម្មតា*

បុគ្គលកាលមិនធ្វើតាមឱវាទរបស់បណ្ឌិត ក៏ដូចជាដើរទៅកាន់ផ្លូវចោរ រមែងដល់សេចក្ដីវិនាសធំ ។

ព្រះពោធិសត្វឲ្យឱវាទ ដល់ព្រះរាជា យ៉ាងនេះហើយ កាលសម្ដែងធម៌ឲ្យក្រៃលែងឡើង ទើបពោលថា

**ធម្មោ បថោ មហារាជ, អធម្មោ បន ឧប្បថោ;**
**អធម្មោ និរយំ នេតិ, ធម្មោ បាបេតិ សុគ្គតិំ។**

បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញ៉ាំងសត្វឲ្យដល់សុគតិ ។

**អធម្មចារិនោ រាជ, នរា វិសមជីវិនោ;**
**យំ គតិំ បេច្ច គច្ឆន្តិ, និរយេ តេ សុណោហិ មេ។**

បពិត្រព្រះរាជា ពួកជនអ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅ

កាន់គតិ (នរក) ណា សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យអាត្មាភាព (ដែលសំដែង) អំពីនរកទាំងនោះ ។

សញ្ជីវោ កាឡសុត្តោ ច, សង្ឃាតោ ទ្វេ ច រោរុវា;
អវីចិ មហាវីចិ, តាបនោ ច បតាបនោ។

សញ្ជីវនរក ១ កាឡសុត្តៈ ១ សង្ឃាតៈ ១ រោរុវៈ ២ នរកដទៃទៀត គឺមហាអវីចិ ១ តាបនៈ ១ បតាបនៈ ១ ។

ឥច្ចេតេ អដ្ឋ និរយា, អក្ខាតា ទុរតិក្កមា;
អាកិណ្ណា លុទ្ទកម្មេហិ, បច្ចេកា សោឡសុស្សទា។

នរកទាំង ៨ នុ៎ះ ដែលអ្នកប្រាជ្ញទាំងឡាយបានសំដែងហើយដោយប្រការដូច្នេះ កម្រមានបុគ្គលណាកន្លងរំលងបាន តាន់តាប់ដោយពួកសត្វដែលមានកម្មអាក្រក់ ចំពោះមហានរកមួយៗ មានឧស្សទនរក ១៦ ។

កទរិយតាបនា ឃោរា, អច្ចិមន្តោ មហព្ភយា;
លោមហំសនរូបា ច, ភេស្មា បដិភយា ទុខា។

*(នរកទាំងនោះ) ជាទីកម្តៅអ្នកកំណាញ់ស្វិត ស្វាញ ជានរកដ៏ពន្ទឹក មានអណ្តាតភ្លើង មានភ័យធំ មានសភាពជាទីព្រឺរោម គួរឲ្យស្ញើម បណ្តាលឲ្យខ្ញបខ្ញាចជាទុក្ខ ។*

ចតុក្កណ្ណា ចតុទ្វារា, វិភត្តា ភាគសោ មិតា;
អយោបាការបរិយន្តា, អយសា បដិកុជ្ជិតា។

*(នរកទាំងនោះ) មានមុំ ៤ មានទ្វារ ៤ ដែលបាបកម្មចែកវាស់ដោយចំណែក មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយក្បឿងដែក ។*

តេសំ អយោមយា ភូមិ, ជលិតា តេជសា យុតា;
សមន្តា យោជនសតំ, ផុដា តិដ្ឋតិ សព្ពទា។

*ភូមិរបស់នរកទាំងនោះ ជាវិការៈនៃដែក ឆេះឡើងប្រកបដោយកម្តៅ (នរកទាំងអស់នោះ) ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វៗ កាល ។*

ឃតេ បតន្តិ និរយេ, ឧទ្ធំបាទា អវំសិរា;
ឥសីនំ អតិវត្តារោ, សញ្ញតានំ តបស្សិនំ។

*ពួកជនអ្នកតិះដៀលពួកឥសី ជាអ្នកសង្រួម មានតបៈនុ៎ះ រមែងធ្លាក់ទៅក្នុងនរកមានជើងឡើងលើ មានក្បាលចុះក្រោម ។*

តេ ភូនហុនោ បច្ចន្តិ, មច្ឆា ពិលកតា យថា;
សំវច្ឆរេ អសង្ខេយ្យេ, នរា កិព្ពិសការិនោ។

*ពួកជនអ្នកធ្វើអំពើអាក្រក់ ជាអ្នកបំផ្លិចបំផ្លាញសេចក្តីចម្រើននោះ ត្រូវពួកនិរយបាលដុត ដូចជាពួកត្រី*

*ដែលគេធ្វើឲ្យជាចំណែក (ដោតអាំង) អស់ឆ្នាំរាប់មិនអស់ ។*

ឧយ្ហមានេ គត្តេន, និច្ចំ សន្តរពាហិរំ;
និរយា ជាតិគច្ឆន្តិ, ទ្វារំ និក្ខមនេសិនោ។

*ពួកសត្វនរក មានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងខាងក្រៅជានិច្ច ស្វែងរកនូវទីចេញ អំពីនរកតែមិនបាននូវទ្វារ ។*

បុរត្ថិមេន ធាវន្តិ, តតោ ធាវន្តិ បច្ឆតោ;
ឧត្តរេនបិ ធាវន្តិ, តតោ ធាវន្តិ ទក្ខិណំ;
យំ យញ្ហិ ទ្វារំ គច្ឆន្តិ, តំ តទេវ បិធីយរេ។

*ពួកសត្វនរកនោះ ស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសខាងកើតនោះ ទៅទិសខាងលិច ស្ទុះទៅទិសខាង*

ជើង ស្ទុះអំពីទិសខាងជើង ទៅទិសខាងត្បូង សត្វនរក ទាំងនោះទៅដល់ទ្វារណាៗ ទ្វារនោះៗ ឯង ក៏បិទជិត ។

ពហូនិ វស្សសហស្សានិ, ជនា និរយគាមិនោ;
ពាហា បគ្គយ្ហ កន្ទន្តិ, បត្វា ទុក្ខំ អនប្បកំ។

ពួកជនដែល ទៅកាន់នរក រងទុក្ខច្រើន ផ្គងដើមដៃ កន្ទក់កន្ទេញ អស់ពាន់នៃឆ្នាំជាច្រើន ។

អាសីវិសំវ កុបិតំ, តេជស្សិំ ទុរតិក្កមំ;
ន សាធុរូបេ អាសីទេ, សញ្ញតានំ តបស្សិនំ។

បុគ្គលមិនគប្បី ចូលទៅបៀតបៀន នូវពួកឥសី ដែលមានសភាពជាសប្បុរស ដូចជាបុគ្គលមិនគួរ ចូលទៅជិតអាសីរពិស ដែលខឹងមានតេជះ គេកន្លងរំលង បានដោយក្រ (ជនទាំងនោះ រមែងធ្លាក់ទៅក្នុងនរក ព្រោះតែបៀតបៀន) នូវពួកឥសីអ្នកសង្រួមមានតបៈ ។

អតិកាយោ មហិស្សាសោ, អជ្ជុនោ កេកកាធិបោ;
សហស្សពាហុ ឧច្ឆិន្នោ, ឥសិមាសជ្ជ គោតមំ។

ព្រះរាជា ព្រះនាមអជ្ជុនៈ មានខ្នាន់ធ្នូដ៏ប្រសើរមានពួកពលដ៏ច្រើន ជាអធិបតីក្នុងដែនឈ្មោះ កេកកៈ អាចលើកធ្នូដែលពួកខ្មាន់ធ្នូ ៥០០ លើកឡើងបានដោយដើមដៃ ១០០០ បៀតបៀនឥសីឈ្មោះ គោតមៈ ហើយវិនាស ។

អរជំ រជសា វច្ឆំ, កិសំ អវកិរិយ ទណ្ឌកី;
តាលោវ មូលតោ ឆិន្នោ, ស រាជា វិភវង្គតោ។

ព្រះរាជាទណ្ឌកី បានបាចរោយធូលី (ស្មោះ) លើតាបស ឈ្មោះ កិសវច្ឆៈ មិនមានធូលី (កិលេស) ព្រះរាជានោះ ក៏ដល់នូវសេចក្ដីវិនាស ដូចជាដើមត្នោតដែលគេកាត់ត្រង់គល់ ។

ឧបហច្ច មនំ មជ្ឈោ, មាតង្គស្មិំ យសស្សិនេ;
សបារិសជ្ជោ ឧច្ឆិន្នោ, មជ្ឈារញ្ញំ តទា អហុ។

*ព្រះរាជាព្រះនាមមជ្ឈៈ ព្រមទាំងបរិស័ទ ញាំងចិត្តឲ្យប្រទូស្ត ក្នុងតាបសឈ្មោះ មាតង្គបណ្ឌិតដ៏មានយស ហើយក៏ដល់នូវសេចក្ដីវិនាស ក្នុងកាលនោះ ដែនឈ្មោះមជ្ឈៈក៏ទៅជាព្រៃ ។*

កណ្ហាទីបាយនាសជ្ជ, ឥសិំ អន្ធកវេណ្ហុយោ;
អញ្ញោញ្ញំ មុសលា ហន្ត្វា, សម្បត្តា យមសាធនំ។

*ពួកព្រះរាជា ជាផៅពង្សអន្ធកវេន្ហុ បៀតបៀននូវឥសីឈ្មោះកណ្ហទីបាយនៈ កាន់យកអង្រែសម្លាប់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក ។*

អថាយំ ឥសិនា សត្តោ, អន្តលិក្ខចរោ បុរេ;
បាវេក្ខិ បឋវឹ ចេច្ចោ, ហីនត្តោ បត្តបរិយាយំ។

ព្រះរាជាព្រះនាមចេតិយៈនេះ កាលពីដើមហោះលើអាកាសបាន ដល់មកខាងក្រោយ ត្រូវកបិលឥសីផ្តាសាហើយ មានអត្តភាព សាបសូន្យចូលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ។

តស្មា ហិ ឆន្ទាគមនំ, នប្បសំសន្តិ បណ្ឌិតា;
អទុដ្ឋចិត្តោ ភាសេយ្យ, គិរំ សច្ចូបសំហិតំ។

ព្រោះហេតុនោះ បានជាពួកបណ្ឌិត មិនសរសើរអគតិ ៤ មានឆន្ទាគតិជាដើមឡើយ បុគ្គលមានចិត្តមិនប្រទូស្ត គប្បីពោលពាក្យប្រកបដោយសច្ចៈ ។

មនសា ចេ បទុដ្ឋេន, យោ នរោ បេក្ខតេ មុនឹ;
វិជ្ជាចរណសម្បន្នំ, គន្តា សោ និរយំ អធោ។

*បើនរៈណាមានចិត្តប្រទូស្តហើយ សម្ងក់ទៅរកអ្នកប្រាជ្ញ ដែលបរិបូរណ៌ ដោយវិជ្ជានិងចរណៈ នរៈនោះនឹងធ្លាក់ទៅក្នុងនរកខាងក្រោម ។*

យេ វុឌ្ឍេ បរិភាសន្តិ, ផរុសូបក្កមា ជនា;
អនបច្ចា អទាយាទា, តាលវត្ថុ ភវន្តិ តេ។

*ពួកជនណាមានសេចក្តីព្យាយាម អាក្រក់ ជេរប្រទេចពួកចាស់ព្រឹទ្ធាចារ្យ ពួកជននោះ (លុះទៅកើតក្នុងភពខាងមុខ) រកកូនគ្មាន រកញាតិគ្មានដូចត្នោតកំបុតគល់ ។*

យោ ច បព្ពជិតំ ហន្តិ, កតកិច្ចំ មហេសិនំ;
ស កាឡសុត្តេ និរយេ, ចិររត្តាយ បច្ចតិ។

ជនណា សម្លាប់បព្វជិតដែលមានកិច្ច ធ្វើហើយ អ្នកស្វែងរកនូវគុណដ៏ធំ ជននោះ រមែងឆេះនៅក្នុង កាឡសុត្តនរកអស់កាល ជាយូរអង្វែង ។

យោ ច រាជា អធម្មដ្ឋោ, រដ្ឋវិទ្ធំសនោ មគោ;
តាបយិត្វា ជនបទំ, តាបនេ បេច្ច បច្ចតិ។

ព្រះរាជាណា មិនតាំងនៅក្នុងធម៌ កម្ចាត់កម្ចាយ អ្នកដែន ដុតកម្ដៅអ្នកជនបទ ព្រះរាជានោះលុះទ្រង់ ទិវង្គតទៅ រមែងឆេះនៅក្នុងតាបននរក ។

សោ ច វស្សសហស្សានិ, សតំ ទិព្ពានិ បច្ចតិ;
អច្ចិសង្ឃបរេតោ សោ, ទុក្ខំ វេទេតិ វេទនំ។

ព្រះរាជានោះក៏ឆេះអស់សែននៃឆ្នាំទិព្វ ព្រះរាជា នោះត្រូវគំនរអណ្ដាតភ្លើងហ៊ុមជុំវិញហើយ ក៏រងទុក្ខ វេទនាខ្លាំង ។

តស្ស អគ្គិសិខា កាយា, និច្ឆរន្តិ បភស្សរា;
តេជោភក្ខស្ស គត្តានិ, លោមេហិ ច នខេហិ ច។

*អណ្តាតភ្លើងទាំងឡាយ ដ៏រន្ទាលប្រាលផ្លោ ផ្សាយចេញអំពីកាយរបស់សត្វនរកនោះ ខ្លួនរបស់សត្វនរក (មានប្រមាណ៣គាវុត) ដែលមានភ្លើង ជាអាហារ (មានអណ្តាតភ្លើងតែមួយជាមួយគ្នា) និងចុងរោមទាំងឡាយផង និងក្រចកទាំងឡាយផង ។*

ឧយ្ហមានេន គត្តេន, និច្ចំ សន្តរពាហិរំ;
ទុក្ខាភិតុន្នោ នទតិ, នាគោ តុត្តដ្ដិតោ យថា។

*សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងខាងក្រៅជានិច្ច ត្រូវសេចក្តីទុក្ខចាក់ដោតហើយ ក៏រោទ៍ដូចជាដំរី ដែលគេចាក់ដោយងៀងកង្វេរ ។*

យោ លោភា បិតរំ ហន្តិ, ទោសា វា បុរិសាធមោ;
ស កាឡសុត្តេ និរយេ, ចិររត្តាយ បច្ចតិ។

*បុរសលាមកណា សម្លាប់បិតា ព្រោះតែលោភៈឬព្រោះទោសៈ បុរសលាមកនោះ រមែងឆេះនៅក្នុង កាឡសុត្តនរកអស់កាល ជាយូរអង្វែង ។*

ស តាទិសោ បច្ចតិ លោហកុម្ភិយំ,
បក្កញ្ច សត្តីហិ ហនន្តិ និត្តចំ;
អន្ធំ ករិត្វា មុត្តករីសភក្ខំ,
ខារេ និមុជ្ជន្តិ តថាវិធំ នរំ។

*បុរសបែបនោះ រមែងឆេះ នៅក្នុងលោហកុម្ភីនរក ពួកនិរយបាល (នាំចេញ) នូវសាច់ដ៏ឆ្អិន ធ្វើមិនឲ្យមានស្បែក ហើយចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យ ខ្វាក់ ឲ្យស៊ីនូវមូត្រនិងលាមក ហើយជ្រមុជជនបែបនោះទៅក្នុងទឹកខារ (ទឹកទង់ដែង) ។*

តត្តំ បក្កុថិតមយោគុឡញ្ច,
ទីឃេ ច ផាលេ ចិររត្តតាបិតេ;
វិក្ខម្ភមាទាយ វិពន្ធរជ្ជុភិ,
វិវដេ មុខេ សម្បវិសន្តិ រក្ខសា។

*ពួកនិរយបាល (ញុំាងសត្វនរកឲ្យស៊ីនូវលាមក) កំពុងពុះ និងដុំដែកដ៏ក្តៅ ហើយយកបណ្តាញដ៏វែង ដែលកម្តៅអស់កាលយូរ មកបើកមាត់ (ហើយបោះសន្ទូចដែក) ដែលចងដោយខ្សែ (ទាញអណ្តាតចេញ ហើយបោះដុំដែក) ទៅក្នុងមាត់ ដែលច្រហនោះ ។*

សាមា ច សោណា សពលា ច គិជ្ឈា,
កាកោលសង្ឃា ច ទិជា អយោមុខា;

សង្គម្ម ខាទន្តិ វិប្ផន្ទមានំ,
ជិវ្ហំ វិភជ្ជ វិឃាសំ សលោហិតំ។

ពួកក្អែកក្រហម ក្អែកពាល ពួកត្មាត ពួកក្អែកនិងពួកសត្វស្វាប (ឯទៀតច្រើនពួក) មានចំពុះដែក នាំគ្នាមកចោមរោមចឹកជញ្ជែងស៊ីនូវអណ្ដាត (នៃពួកសត្វនរក) ដែលញាប់ញ័រ (ដូចជាស៊ី) នូវរំពាព្រមទាំងឈាម មានឈាមកំពុងហូរចេញ ។

តំ ទឡ្ហតាលំ បរិភិន្នគត្តំ,
និប្បោថយន្តា អនុវិចរន្តិ រក្ខសា;

រតី ហិ តេសំ ទុខិនោ បនីតរេ,
ឃតាទិសស្មឹ និរយេ វសន្តិ;
យេ កេចិ លោកេ ឥធ បេត្តិឃាតិនោ។

ពួកនិរយបាលវាយសំពងសត្វនរកនោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយេះរយាយ ដោយតម្រេករបស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរក ទាំងឡាយ

ក្រោនេះ ក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណានីមួយក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជននោះ តែងទៅនៅក្នុងនរកបែបនុ៎ះ ។

បុត្តោ ច មាតរំ ហន្ត្វា, ឥតោ គន្ត្វា យមក្ខយំ;
កុសមាបជ្ជតេ ទុក្ខំ, អត្តកម្មផលូបគោ។

កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្ម របស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ។

អមនុស្សា អតិពលា, ហន្តារំ ជនយន្តិយា;
អយោមយេហិ វាលេហិ, បីឡយន្តិ បុនប្បុនំ។

ពួកអមនុស្ស (និរយបាល) ព្រហើនក្រៃលែង យកសរសៃដែក (មករុំ) នូវបុគ្គលអ្នកសម្លាប់មាតា ហើយគាប (ដោយឃ្នាបដែក) រឿយៗ ។

តមស្សុវំ សកា គត្តា, រុធិរំ អត្តសម្ភវំ;
តម្ពលោហវិលីនំវ, តត្តំ ចាយេន្តិ មត្តិឃំ។

*ពួកនិរយបាល ញុំាងបុគ្គលអ្នកសម្លាប់មាតានោះឲ្យផឹកនូវឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួនដូចជាទឹកទង់ដែងរលាយ ។*

ជិគុច្ឆំ កុណបំ បូតិំ, ទុគ្គន្ធំ គូថកទ្ទមំ;
បុព្ពលោហិតសង្កាសំ, រហទមោគយ្ហ តិដ្ឋតិ។

*បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅឋិតនៅក្នុង រណ្តៅគូរខ្ពើម ដូចជាអសុភមានក្លិនស្អុយ មានលាមកជាភក់ មានក្លិនអាក្រក់ ប្រហែលគ្នា ដោយខ្ទុះនិងឈាម ។*

តមេនំ កិមយោ តត្ថ, អតិកាយា អយោមុខា;
ឆវឹ ភេត្វាន ខាទន្តិ, សំគិទ្ធា មំសលោហិតេ។

*ក្នុងនរកនោះមានពួកដង្កូវ មានខ្លួនធំ មានមាត់ដូចម្ជុលដែក រុកត្បុល ចូលទៅក្នុងសាច់ និងឈាម ទម្លាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ ( ទាំងខួរក្នុងឆ្អឹង) ។*

សោ ច តំ និរយំ បត្តោ, និមុគ្គោ សតបោរិសំ;
បូតិកំ កុណបំ វាតិ, សមន្តា សតយោជនំ។

*បុគ្គលអ្នក សម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះ ជ្រមុជ (ក្បាល) ចុះទៅ ចំនួនមួយរយជួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទីចម្ងាយ មួយរយយោជន៍ជុំវិញ ។*

ចក្ខុមាបិ ហិ ចក្ខូហិ, តេន កម្មេន ជីយតិ;
ឯតាទិសំ ព្រហ្មាទត្ត, មាតុឃោ លភតេ ទុខំ។

ព្រោះថា សូម្បីជនមានចក្ខុ ធុញទ្រាន់ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្ដីទុក្ខបែបនេះ ។

ខុរធារមនុក្កម្ម, តិក្ខំ ទុរភិសម្ភំ;
បតន្តិ គព្ភចាតិយោ, ទុក្ខំ វេតរណឹ នទឹ។

ពួកស្ត្រីរំលូតគភ៌ កន្ទង់នូវខុរធារនរកដ៏មុត ដែលគេគ្រប់សង្កត់ បានដោយក្រ ធ្លាក់ទៅក្នុងស្ទឹង ឈ្មោះ វេតរណី ដែលមិនរាបស្មើ ។

អយោមយា សិម្ពលិយោ, សោឡសង្គុលកណ្ដកា;
ឧភតោ អភិលម្ពន្តិ, ទុក្ខំ វេតរណឹ នទឹ។

ដើមរកាទាំងឡាយ ជាវិការៈនៃដែក មានបន្លាប្រវែង ១៦ ធ្នាប់ សំយុងចុះមកត្រង់ត្រើយ ទាំងពីរខាងនៃស្ទឹងឈ្មោះវេតរណី ដែលមិនរាបស្មើ ។

តេ អច្ចិមន្តោ តិដ្ឋន្តិ, អគ្គិក្ខន្ធាវ អារកា;
អាទិត្តា ជាតវេទេន, ឧទ្ធំ យោជនមុគ្គតា។

ដើមរកាទាំងនោះ ត្រូវភ្លើងឆេះ មានអណ្តាតខ្ពស់ឡើងទៅលើ ១ យោជន៍ ដូចជាគំនរភ្លើង អំពីឆ្ងាយ ។

ឯតេ វជន្តិ និរយេ, តត្តេ តិខិណកណ្ឋកេ;
នារិយោ ច អតិចារា, នរា ច បរទារគូ។

ពួកស្ត្រីប្រព្រឹត្តក្បត់ចិត្តប្តី និងពួកប្រុសដែលគប់រកប្រពន្ធគេ ជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលីនរកដែលក្តៅ មានបន្លាស្រួច ។

តេ បតន្តិ អធោក្ខន្ធា, វិវត្តា វិហតា បុថូ;
សយន្តិ វិនិវិទ្ធង្គា, ទីឃំ ជគ្គន្តិ សព្ពទា។

ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម ត្រូវពួកនិរយបាលចាក់ (ដោយអាវុធ) ច្រើនដង ក៏វិលធ្លាក់

មកវិញ មានខ្លួនធុះធ្លាយ រមែងដេក រមែងភ្ញាក់ អស់កាលជាយូរអង្វែង សព្វៗ កាល ។

តតោ រត្យា វិវសានេ, មហាតិំ បព្វតូបមំ;
លោហកុម្ភិំ បវជ្ជន្តិ, តត្តំ អគ្គិសមូទកំ។

(ពួកសត្វនរក ត្រូវពួកនិរយបាល ចាប់បោះទៅ) ក្នុងនរកឈ្មោះ លោហកុម្ភី មានឧបមាដោយភ្នំដ៏ធំ មានទឹកស្មើនិងភ្លើង ដ៏ក្តៅ រមែងឆេះអស់កាលកន្លងទៅនៃរាត្រីជាយូរអង្វែង ។

ឯវំ ទិវា ច រត្តោ ច, ទុស្សីលា មោហបារុតា;
អនុភោន្តិ សកំ កម្មំ, បុព្វេ ទុក្កដមត្តនោ។

ពួកមនុស្សទ្រុស្តសីល (គប់រកប្រពន្ធគេ) ដែលមោហៈគ្របសង្កត់ហើយ រមែងរងកម្ម របស់ខ្លួនដែលខ្លួនធ្វើអាក្រក់ក្នុងកាលមុន ទាំងថ្ងៃទាំងយប់យ៉ាងនេះ ។

យា ច ភរិយា ធនក្កីតា, សាមិកំ អតិមញ្ញតិ;
សស្សុំ វា សសុរំ វាបិ, ជេដ្ឋំ វាបិ ននន្ទរំ។

ប្រពន្ធណា ដែលគេទិញមកដោយទ្រព្យ មើលងាយប្តី ម្តាយក្មេក ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃស្រី ។

តស្សា វង្កេន ជិវ្ហគ្គំ, និព្ពហន្តិ សពន្ធនំ;
ស ព្យាមមត្តំ កិមិនំ, ជិវ្ហំ បស្សតិ អត្តនិ;
វិញ្ញាបេតុំ ន សក្កោតិ, តាបនេ បេច្ច បច្ចតិ។

ពួកនិរយបាល តែងទាញដកអណ្តាត ព្រមទាំងគល់របស់នាងនោះ ព្រមទាំងចំណង ដោយសន្ទូច សត្វនរកនោះ ឃើញអណ្តាត របស់ខ្លួនប្រមាណមួយព្យាមពេញដោយដង្កូវ មិនអាចអង្វរ (ពួកនិរបាល) បាន លុះស្លាប់ទៅរមែងឆេះនៅក្នុងតាបននរកទៀត ។

ឱរព្ភិកា សូករិកា, មច្ឆិកា មិគពន្ធកា;
ចោរា គោឃាតកា លុទ្ទា, អវណ្ណេ វណ្ណការកា។

ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ទាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើគុណក្នុងទោស (អ្នកញុះញង់) ។

សត្តីហិ លោហកូដេហិ, នេត្តិំសេហិ ឧសូហិ ច;
ហញ្ញមានា ខារនទិំ, បបតន្តិ អវំសិរា។

ពួកសត្វនរកនោះ ត្រូវពួកនិរយបាលបៀតបៀនដោយលំពែង ដោយញញួរលោហៈ ដោយសំសែ ដោយព្រួញទាំងឡាយ មានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងស្ទឹងខារ ។

សាយំ បាតោ កូដការី, អយោកូដេហិ ហញ្ញតិ;
តតោ វន្តំ ទុរត្តានំ, បរេសំ ភុញ្ជរេ សទា។

អ្នកធ្វើអំពើវៀច ត្រូវពួកនិរយបាល ដំដោយញញួរដែកទាំងឡាយ ទាំងល្ងាចទាំងព្រឹក ហើយស៊ីនូវកម្អួតរបស់ពួកសត្វនរកដទៃ ដែលមានអត្តភាពអាក្រក់នោះ សព្វៗ កាល ។

ជង្ឃា កេរណ្ឌកា គិជ្ឈា, កាកោលា ច អយោមុខា;
វិប្ផន្ទមានំ ខាទន្តិ, នរំ កិព្ពិសការកំ។

ពួកក្អែក ចចក ត្មាត ក្អែកព្រៃ មានចំពុះដែក នាំគ្នាចឹកប្រជែង នូវជនអ្នកធ្វើអំពើអាក្រក់កំពុងញាប់ញ័រ ។

យេ មិគេន មិគំ ហន្តិ, បក្ខឹ វា បន បក្ខិនា;
អសន្តោ រជសា ឆន្នា, គន្តា តេ និរយុស្សទំ។

ពួកជនណាសម្លាប់ម្រឹគ ដោយម្រឹគ សម្លាប់បក្សីដោយបក្សី ពួកជននោះជាអសប្បុរស បិទបាំងដោយធូលី គឺរាគាទិក្កិលេស រមែងទៅកាន់ឧស្សទនរក ។

ពាក្យថា **ធម៌ជាផ្លូវត្រូវ** បានដល់ ធម៌គឺកុសល-កម្មបថ ១០ ជាផ្លូវទៅកាន់សុគតិ ដែលក្សេម មិនមានភ័យចំពោះមុខ ។ ពាក្យថា **ចិញ្ចឹមជីវិតខុសគន្លងធម៌** បានដល់ សម្រេចការចិញ្ចឹមជីវិតដោយអធម៌ ។ ពាក្យថា (**សំដែង**) **នរកនោះដល់ព្រះអង្គ** សេចក្ដីថា អាត្មានឹងសម្ដែងនរកជាទីកើតនៃសត្វនោះដល់ព្រះអង្គ ។ ពាក្យថា **សូមព្រះអង្គ ទ្រង់ព្រះសណ្ដាប់ពាក្យអាត្មាភាព** សេចក្ដីថា មហាសត្វសូម្បីត្រូវព្រះរាជាត្រាស់សួរដល់នរកជាទីកើត នៃពួកជនអ្នកសម្លាប់បិតា ក៏ដោយ ក៏មិនបានសម្ដែងនរកនោះមុន ហើយទើបពោលយ៉ាងនេះ ដើម្បីនឹងសម្ដែងមហានរក ៨ រណ្ដៅ និងឧស្សទនរក ១៦ រណ្ដៅ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថា កាលព្រះមហាសត្វសម្ដែងនរក ដែលព្រះរាជាត្រាស់សួរនោះមុន ព្រះរាជានឹងគប្បីបែកព្រះហឫទ័យ សោយទិវង្គតក្នុងទីនោះឯងព្រះរាជាកាលឃើញសត្វដែលឆេះក្នុងនរកទាំងឡាយទ្រង់រមែងកាន់យកជាទិដ្ឋានុគតិ មានឧបត្ថម្ភកកម្មកើតឡើងព្រមហើយ ដោយគិតថា សូម្បីសត្វដទៃជាច្រើនក៏មានបាបកម្ម ដូចយើង យើងនឹងឆេះក្នុងចន្លោះនៃសត្វទាំងនោះ ដូច្នេះហើយ ទ្រង់នឹងជាអ្នកមិនមានរោគ ចំណែកព្រះមហាសត្វកាលសម្ដែងនរកដល់ព្រះរាជានោះ បានធ្វើផែនដីឲ្យបែកជាពីរ ដោយកម្លាំងឫទ្ធិហើយ ទើបសម្ដែងជាខាងក្រោយ ។

## សេចក្ដីអធិប្បាយពីមហានរក ៨ រណ្ដៅ

សត្វនរកទាំងឡាយណា ត្រូវនាយនិរយបាលកាន់អាវុធផ្សេងៗ ដែលឆេះសន្ធោសន្ធៅ កាត់ជា

កំណាត់តូចកំណាត់ធំ ធ្វើឲ្យជាចំណែកៗហើយ រមែង មានជីវិតវិញ រឿយៗ មានក្នុងនរកនោះ ព្រោះហេតុ នោះ នរកនោះ ឈ្មោះថា **សញ្ជីវៈ** ។

នាយនិរយបាលទាំងឡាយស្រែកហ៊ោ កញ្ជ្រៀវ រឿយៗ កាន់អាវុធផ្សេងៗ ដែលឆេះសព្វអន្ទើ ដេញ តាមខាងក្រោយសត្វនរក លើផែនដីដែក ដែលឆេះ ហើយប្រហារ កាលសត្វនរកដួលលើផែនដីដែលឆេះ យកខ្សែតីខ្មៅ ចងអូសទាញ ហើយកាន់យកពូថៅ ដែលឆេះ ស្រែកគំរាម ធ្វើសត្វនរកដែលកំពុងស្រែក យំ ដោយសំឡេងថ្ងូរដ៏ខ្លាំង ឲ្យជា ៨ ចំណែក និង ១៦ ចំណែក ហើយកាប់ចាំងក្នុងនរកនោះ ព្រោះហេតុ នោះ នរកនោះ ឈ្មោះថា **កាឡសុត្តៈ** ។

ភ្នំដែក ដែលឆេះ ដ៏ធំទាំងឡាយ បៀតបៀនសម្លាប់សត្វ ក្នុងនរកនោះ ព្រោះហេតុនោះ នរកនោះឈ្មោះថា **សង្ឃាតៈ** ។ បានឮថា នាយនិរយបាលធ្វើសត្វនរកឲ្យចូលទៅ ក្នុងផែនដីដែក ដែលឆេះ ដែលមានទំហំ ៩ យោជន៍ លិចកប់ត្រឹមចង្កេះ មិនកម្រើក ។ លំដាប់នោះ ភ្នំដែកដែលឆេះ តាំងឡើងអំពីទិសខាងកើត ស្រែកគំរាម ដូចជារន្ទះបាញ់ រមៀលមកកិនសត្វទាំងនោះ ដូចគេធ្វើបុកគ្រាប់ល្ងឲ្យល្អិត ហើយទៅបិតទិសខាងលិច សូម្បីតាំងឡើងអំពីទិសខាងលិច ក៏ទៅយ៉ាងនោះ មកបិតនៅទិសខាងកើត ។ ភ្នំទាំងពីរនោះរមៀលមកបុកគ្នា បៀតបៀនសត្វនរក ដូចជា ម៉ាស៊ីនគាបកំណាត់អំពៅ ។ សត្វនរកទាំងឡាយរមែងសោយសេចក្ដីទុក្ខក្នុងសង្ឃាតនរកនោះ អស់ច្រើនសែនឆ្នាំដោយប្រការយ៉ាងនេះ ។

ពាក្យថា **រោរុវនរក** ២ បានដល់ ជាលរោរុវៈ និង ធូមរោរុវៈ ។ បណ្តារោរុវនរកទាំងពីរនោះ ជាលរោរុវៈពេញទៅដោយសំណាញដែកក្រហម តាំងនៅរហូតកប្ប ឯធូមរោរុវៈពេញផេះនិងផ្សែង ។ ក្នុងរោរុវៈទាំងពីរនោះ អណ្តាតភ្លើងចូលទៅតាមមាត់ដំបៅទាំង ៩ របស់សត្វនរក ដែលកំពុងឆេះ ក្នុងជាលរោរុវៈហើយទើបដុតសរីរៈ ចំណែកផេះនិងផ្សែងចូលទៅតាមមាត់ដំបៅទាំង ៩ របស់សត្វនរក ដែលកំពុងឆេះក្នុងធូមរោរុវៈហើយ ទើបចំហុយសរីរៈ ហាក់ដូចជាម្សៅ ។ សត្វនរកដែលកំពុងឆេះ ក្នុងនរកទាំងពីរនោះ រមែងស្រែកយំដោយសំឡេងដ៏ខ្លាំង ព្រោះហេតុនោះ លោកទើបហៅនរកទាំងពីរនោះថា **រោរុវៈ** ។

រវាងចន្លោះ នៃអណ្តាតភ្លើងក្តី សត្វនរកដែលកំពុងឆេះក្តី សេចក្តីទុក្ខរបស់សត្វនរកនោះក្តី មិនមាន

ក្នុងនរកនោះ ព្រោះហេតុនោះ នរកនោះ ឈ្មោះថា **អវីចិ**, អវីចិនរកជាស្ថានដ៏ធំ ទើបឈ្មោះថា **មហាអវីចិ**។ មែនពិត ក្នុងមហាអវីចិនរកនោះ អណ្តាតភ្លើងតាំងឡើងអំពីជញ្ជាំងទិសខាងកើតជាដើម ឆេះរាលដាលមកខ្ទាំងខ្ទប់ នឹងជញ្ជាំង នៅទិសខាងលិចជាដើម អណ្តាតភ្លើងនោះចាក់ទម្លុះជញ្ជាំងហើយ ឆេះទៅខាងមុខ បានប្រមាណ ១០០ យោជន៍ ។ អណ្តាតភ្លើងដែលតាំងឡើងខាងក្រោម ឆេះមកខ្ទាំងខ្ទប់ ដល់ខាងលើ អណ្តាតភ្លើងដែលតាំងឡើងខាងលើ ឆេះមកខ្ទាំងខ្ទប់ ដល់ខាងក្រោម ។ ព្រោះហេតុនោះ ទើបឈ្មោះថា អណ្តាតភ្លើង ក្នុងមហាអវីចិនរកនេះ រមែងមិនមានចន្លោះ ដោយប្រការយ៉ាងនេះ ។ ខាងក្នុងមហាអវីចិនរកនោះ មានស្ថានទី ១០០ យោជន៍ ដែលពេញដោយសត្វនរក រកចន្លោះគ្មាន ហាក់បីដូចជានាឡិ

ដែលពេញដោយទឹកដោះស្រស់ និងម្សៅ ប្រមាណនៃសត្វដែលកំពុងឆេះ រមែងមិនមាន ដោយឥរិយាបថទាំង ៤ សត្វនរកទាំងនោះ បៀតបៀននូវគ្នានឹងគ្នារមែងឆេះក្នុងនៅស្ថានទីរបស់ខ្លួន ។ ព្រោះហេតុនោះទើបឈ្មោះថា ចន្លោះនៃសត្វក្នុងមហាអវីចិនរកនោះរមែងមិនមាន ដោយប្រការយ៉ាងនេះ ។ ទឹកឃ្មុំ ៦ដំណក់ ដែលនៅនឹងចុងអណ្ដាត រមែងជាអព្វោហារិក(យកជាការមិនបាន) ព្រោះដំណក់ទឹកទង់ដែង ជាគម្រប់ ៧ ជារបស់មានកម្លាំងដុតពោលរឿយៗ យ៉ាងណា ឧបេក្ខាវេទនាដែលជាអកុសលវិបាក ៦ (គឺឧបេក្ខាសហគតចក្ខុវិញ្ញាណ ១ ឧបេក្ខាសហគត-សោតវិញ្ញាណ ១ ឧបេក្ខាសហគតឃានវិញ្ញាណ ១ឧបេក្ខាសហគតជិវ្ហាវិញ្ញាណ ១ ឧបេក្ខាសហគត-សម្បដិច្ឆនចិត្ត ១ និងឧបេក្ខាសហគតសន្តីរណោចិត្ត ១)

ដ៏សេស រមែងជាអព្វោហារិក ព្រោះសេចក្ដីទុក្ខក្នុង មហាអវីចិនរកនោះ មានកម្លាំង ដុតពោលរឿយៗ ក៏យ៉ាងនោះ សេចក្ដីទុក្ខប៉ុណ្ណោះ រមែងប្រាកដ ។ ព្រោះហេតុនោះ ទើបឈ្មោះថា ចន្លោះនៃសេចក្ដីទុក្ខ រមែងមិនមាន ក្នុងមហាអវីចិនរកនោះ ដោយប្រការ យ៉ាងនេះ ។ មហាអវីចិនរកនេះ វាស់ដោយជញ្ជាំងទាំងឡាយ មានប្រមាណ ៣១៨ យោជន៍, វាស់ដោយជុំវិញ មានប្រមាណ ៩៥៤ យោជន៍, រួមទាំងឧស្សទនរកផង មានប្រមាណ ១ ម៉ឺនយោជន៍ ។ អ្នកសិក្សាគប្បីជ្រាបថា មហាអវីចិនរកនោះ មានភាពធំ យ៉ាងនេះ ។

នរកណាដុតសត្វនរក មិនឲ្យកម្រើកបាន ព្រោះហេតុនោះ នរកនោះ ឈ្មោះថា **តាបនៈ** ។ នរកណាដុតសត្វនរកឲ្យក្ដៅខ្លាំងដ៏ក្រៃលែង ព្រោះហេតុនោះ នរក

នោះ ឈ្មោះថា **បតាបនៈ** ។ ជាដំបូង នាយនិរយបាលទាំងឡាយឲ្យសត្វនរកអង្គុយ លើលំពែងដែក ដែលឆេះមានប្រមាណប៉ុនដើមត្នោត ក្នុងតាបននរកនោះ ហើយផែនដីឆេះអំពីខាងក្រោម, ដែកអណ្ដាតនោះក៏ឆេះ, សត្វនរកទាំងឡាយក៏ឆេះរុងរឿងដែរ ។ តាបន-នរកនោះ រមែងដុតកម្ដៅសត្វនរក មិនឲ្យកម្រើក យ៉ាងនេះ ។ ម្យ៉ាងទៀត នាយនិរយបាលប្រហារសត្វដែលកើតក្នុងនរកនោះ ដោយអាវុធទាំងឡាយ ដែលឆេះដេញឲ្យឡើងលើភ្នំដែកដែលកំពុងឆេះ ។ ក្នុងវេលាដែលសត្វទាំងនោះ ឈរនៅលើកំពូលភ្នំ ខ្យល់ដែលមានកម្មជាបច្ច័យ រមែងប្រហារសត្វទាំងនោះ ។ សត្វនរកមិនអាចនឹងតាំងនៅ លើកំពូលភ្នំបាន មានជើងឡើងលើ ក្បាលសំយុងចុះក្រោម ធ្លាក់មក ។ លំដាប់នោះ លំពែងដែកដែលឆេះ ផុសតាំងឡើងអំពីផែនដី

ដែក នៅខាងក្រោម ។ សត្វនរកទាំងនោះ ត្រូវប្រហារដោយចុងលំពែង សរីរៈដែលមុត បែក ធ្លុះធ្លាយ ដោយលំពែងនោះ ក៏ត្រូវឆេះរោលរាល ។ នរកនោះ រមែងដុតសត្វនរកឲ្យក្តៅក្រហាយក្រៃលែងយ៉ាងនេះ ។

ព្រះពោធិសត្វ កាលនឹងសម្តែងនរក ទាំងនោះ ទើបពោលសញ្ជីវនរកជាដំបូង (ព្រោះ) បានឃើញនេរយិកសត្វទាំងឡាយឆេះក្នុងសញ្ជីវនរកនោះ ញុំាងភ័យធំឲ្យកើតដល់មហាជន (បន្ទាប់មក) លោកក៏ញុំាងសញ្ជីវនរកនោះឲ្យបាត់ទៅ ធ្វើផែនដីដែលបែកជាពីរ សម្តែងនូវកាឡសុត្តនរក ហើយឃើញសត្វនរកកំពុងឆេះសូម្បីក្នុងកាឡសុត្តនរកនោះ ញុំាងភ័យធំឲ្យកើតដល់មហាជនហើយ លោកក៏ឲ្យកាឡសុត្តនរកនោះបាត់ទៅ ព្រះពោធិសត្វសម្តែងមហានរកតាមលំដាប់ដោយប្រការដូច្នេះ ។ លំដាប់នោះ ព្រះពោធិសត្វទើប

យាងព្រះរាជាមកហើយ ទូលថា បពិត្រមហារាជ ព្រះអង្គបានឃើញសត្វទាំងឡាយ ដែលកំពុងឆេះ ក្នុងមហានរកទាំងឡាយ ៨ នេះហើយ សូមទ្រង់គួរធ្វើសេចក្តីមិនប្រមាទ យ៉ាងនេះហើយ កាលនឹងពោលដល់កិច្ច របស់មហានរកទាំងនោះ ទើបពោលថា នរក ៨ រណ្តៅ ។

ពាក្យថា **ពោលហើយ** សេចក្តីថា នរក ៨ រណ្តៅ ដែលអាត្មាពោលហើយដល់ព្រះអង្គនេះ គឺបោរាណបណ្ឌិតទាំងឡាយ បានពោលហើយ ។ ពាក្យថា **ចំពោះមហានរកមួយៗ មានឧស្សទនរក ១៦** សេចក្តីថា មហានរក ៨ រណ្តៅនោះ រណ្តៅនីមួយៗមានទ្វារ ៤ ទ្វារនីមួយៗ មានឧស្សទនរក ៤ ដូច្នេះ មហានរកនីមួយៗ ទើបមានឧស្សទនរក ១៦ ៗ រណ្តៅ រួមឧស្សទនរកទាំងអស់ មាន ១២៨ រណ្តៅ បូករួមនឹងមហានរក

៨ រណ្ដៅផង ទើបមាននរក ១៣៦ រណ្ដៅ ។ ពាក្យថា **(នរកទាំងនោះ) មានមុំ ៤** សេចក្ដីថា នរកសូម្បីទាំងអស់ ប្រាកដដូចជា ហិប ៤ ជ្រុង ។ ពាក្យថា **មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយគ្រឿងដែក** សេចក្ដីថា នរក សូម្បីទាំងអស់ បិទបាំងដោយគ្រឿងដែក មានប្រមាណ ៩ យោជន៍ ។ ចំណែកនរកទាំងនោះ នឹងជាក់ច្បាស់ក្នុងនិមិជាតក (នេមិរាជ) ។

ព្រះមហាសត្វ កាលសម្ដែងនរក មានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ក៏ធ្វើការបើកទេវលោកសម្ដែងដល់ព្រះរាជា ទើបពោលថា

**សង្កោ ច ឧទ្ធំ គច្ឆន្តិ, សុចិណ្ណេនិធ កម្មុនា;**
**សុចិណ្ណស្ស ផលំ បស្ស, សឥន្ទា ទេវា សព្រហ្មកា។**

ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អ ហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គទត មើលផលនៃអំពើដែលគេបានសន្សំល្អ ដូចពួកទេវតា ព្រមទាំង ព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម ។

តំ តំ ព្រូមិ មហារាជ,
ធម្មំ រដ្ឋបតី ចរ;
តថា រាជ ចរាហិ ធម្មំ,
យថា តំ សុចិណ្ណំ ជានុតប្បេយ្យ បច្ឆា។

បពិត្រមហារាជ អាត្មាភាពពោលហេតុនោះ នឹងព្រះអង្គ បពិត្រព្រះអង្គជាម្ចាស់នៃដែន សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីដុតកម្ដៅរឿយៗ ក្នុងកាលជាខាងក្រោយយ៉ាងណាៗ សូមព្រះអង្គ ប្រព្រឹត្តធម៌យ៉ាងនោះៗ ចុះ ។

ព្រះមហាសត្វ កាលសម្ដែងទេវលោក មានឋាន ចាតុមហារាជជាដើមហើយ ក៏ទូលថា បពិត្រមហារាជ សូមព្រះអង្គទតទេវលោកជាន់ចាតុមហារាជិកា ចូរទត មើលស្ដេចមហារាជទាំង ៤ ចូរមើលឋានតាវត្តិង្ស ចូរ មើលសក្កទេវរាជ ដូច្នេះហើយ កាលសម្ដែងទេវលោក ព្រមទាំងព្រះឥន្ទ្រ និងព្រះព្រហ្មហើយ សូម្បីទាំងអស់ យ៉ាងនេះហើយ ទើបសម្ដែងតទៅថា នេះជាផលនៃ កម្មដែលប្រព្រឹត្តល្អ សូម្បីនេះក៏ជាផលនៃកម្មដែល បុគ្គលប្រព្រឹត្តល្អ ។ ពាក្យថា **ប្រព្រឹត្តធម៌** សេចក្ដីថា ចាប់ ពីថ្ងៃនេះទៅ សូមព្រះអង្គលះបង់ បញ្ចវេរទាំងឡាយ មានបាណាតិបាតជាដើម ចូរធ្វើបុណ្យទាំងឡាយមាន ឲ្យទានជាដើមចុះ ។ ពាក្យថា **អំពើដែលព្រះអង្គប្រព្រឹត្ត ល្អនោះ មិនគប្បីដុតកម្ដៅរឿយៗ ក្នុងកាលជាខាង ក្រោយយ៉ាងណា។** សេចក្ដីថា សូមព្រះអង្គប្រព្រឹត្តធម៌ នោះឲ្យល្អ គឺចូរធ្វើបុញ្ញកម្ម មានទានជាដើម ជាកម្ម ដែលបុគ្គលសន្សំល្អហើយ រមែងមិនតាមដុត ដើម្បី

បិទបាំងសេចក្តីក្តៅក្រហាយ ស្តាយក្រោយ ដែលមាន បិតុឃាតកម្មជាបច្ច័យ យ៉ាងណា សូមទ្រង់ប្រព្រឹត្ត សន្សំកម្មនោះឲ្យល្អ និងធ្វើបុណ្យ ឲ្យច្រើនយ៉ាងនោះ ចុះ ។

ព្រះរាជានោះ ស្តាប់ធម្មកថា របស់ព្រះមហាសត្វ ហើយ ចាប់ពីពេលនោះមក ព្រះអង្គក៏បានការធូរ ស្បើយចិត្ត ។ ចំណែកព្រះពោធិសត្វនៅក្នុងទីនោះ អស់ប្រមាណបន្តិចហើយ ក៏ទៅកាន់លំនៅរបស់ខ្លួន វិញ ។

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះ មកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាល ឥឡូវនេះទេ សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើព្រះ រាជានេះបានធូរស្បើយចិត្តដូចគ្នាដែរ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា

**តទា រាជា អជាតសត្តុ អហោសិ** *ព្រះរាជាក្នុងកាលនោះ បានមកជាព្រះបាទអជាតសត្តុ*

**ឥសិគណោ ពុទ្ធបរិសា** *ពួកឥសីបានមកជាពុទ្ធបរិស័ទ*

**សំកិច្ចបណ្ឌិតោ បន អហមេវ អហោសិំ** *ចំណែកសំកិច្ចបណ្ឌិតគឺតថាគតនេះឯង ។*

*សង្កិច្ចជាតក ចប់ ៕*

( *ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សដ្ឋិនិបាត បិដក លេខ ៦១ ទំព័រ ៥៣* )

*ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ត្រូវនឹងថ្ងៃទី ៨ ខែមិថុនា ព.ស. ២៥៦២ គ.ស. ២០១៨*

*ដោយស.ដ.វ.ថ.*